# បណ្ណាល័យស្រមើស្រមៃរបស់

## DOLLY PARTON



## ការអានជាមួយកូនអ្នកជាភាសាផ្សេងៗគ្នា

ការអាននិងប្រើសៀវភៅរូមគ្នាជាមួយកូនអ្នកផ្តល់ផលប្រយោជន៍ជាច្រើន ហើយការចាប់ផ្តើមធ្វើវាមិនដែលរហ័សពេកនោះទេ។ ចាប់ពីអាយុក្មេងខ្ចីទៅ កូនអ្នកនឹងរៀនអំពីសំឡេង ពាក្យ និងភាសាពីបទពិសោធន៍ទាំងនេះ ហើយវាក៏នឹងជួយដល់ការរីកចម្រើនផ្នែកសង្គមនិងផ្លូវចិត្តរបស់កូនអ្នកផងដែរ។

សូមកុំបារម្ភ បើអង់គ្លេសមិនមែនជាភាសាដំបូងរបស់គ្រួសារអ្នក។ អ្វីដែលសំខាន់គឺថា អ្នកប្រើសៀវភៅរូមគ្នាជាមួយកូនអ្នកជាភាសាអ្វីក៏ដោយ ឬការលាយចូលគ្នានូវភាសានានាដែលអ្នកមានអារម្មណ៍កក់ក្តៅបំផុត។

## នេះជាគន្លឹះខ្លះដើម្បីទទួលផលប្រយោជន៍ល្អបំផុតពីសៀវភៅរបស់បណ្ណាល័យស្រមើស្រមៃ ទោះជាអ្នកប្រើភាសាអ្វីក៏ដោយ។

ជាដំបូង សូមស្វែងរកកន្លែងកក់ក្តៅនិងស្ងប់ស្ងាត់ ដែលអ្នកនឹងគ្មានការរំខាន។ នេះជាពេលម្នាក់ទល់នឹងម្នាក់ដ៏ពិសេសរបស់អ្នក ហើយត្រូវបានធ្វើជារៀងរាល់ថ្ងៃ។ វានឹងក្លាយយ៉ាងរហ័សទៅជាអ្វីដែលអ្នកនិងកូនអ្នកទន្ទឹងរង់ចាំធ្វើ។

មើលក្របសៀវភៅនិងនិយាយអំពីអ្វីដែលអ្នកឃើញ។ ហៅវត្ថុនីមួយៗ។ បើកូនអ្នកមានវ័យធំគ្រប់គ្រាន់ សួរកូនតើកូនយល់ថារឿងនោះគឺអំពីអ្វី។

បើកទំព័រនីមួយៗ ចំណាយពេលដើម្បីស្វែងរករូបភាព ហើយប្រាប់រឿងទៅតាមពាក្យពេចន៍និងភាសារបស់អ្នកផ្ទាល់ ដោយប្រើរូបភាពពន្យល់នៅពេលប្រាប់ឲ្យធ្វើ។ នៅពេលដែលអ្នកធ្វើ សូមជំរុញទារកអ្នកឲ្យចង្អុលស្ទាប ឬកាន់សៀវភៅ។ បើកូនមានអាយុច្រើនជាងនេះ កូនអ្នកអាចកាន់សៀវភៅនិងបើកទំព័រ។

សូមខិតខំប្តូរសំឡេងរបស់អ្នកនៅពេលដែលអ្នកនិយាយអំពីរូបភាពឬប្រាប់រឿង។ បើសៀវភៅនេះរំលឹកអ្នកអំពីចម្រៀងឬពាក្យច្លួន សូមច្រៀងបន្តិចឲ្យកូនអ្នកស្តាប់។

សម្រាប់កូនអាយុច្រើន សូមសួរសំណួរនិងផ្តល់ចម្លើយ។ និយាយជាមួយកូនអ្នកអំពីតួអង្គនិងរឿង និងអំពីអ្វីដែលអ្នកគិតថាប្រហែលជាកើតមានឡើងនៅគ្រាបន្ទាប់។

ដើម្បីស្វែងយល់បន្ថែមអំពីបណ្ណាល័យស្រមើស្រមៃរបស់ Dolly Parton នៅក្នុងប្រទេសអូស្ត្រាលី សូមចូលទៅកាន់វិបសៃរបស់យើង
unitedway.com.au/imagination-library